ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៥០៤ MIH / 2014

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ៤៦១ MIH/2014 ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការចេញកែសម្រួល បន្ត ព្យួរ និងដកហូតប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មទឹកស្អាតរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## <u>សម្រេច</u>

**<u>ប្រការ១</u> ៖**

ត្រូវបានចាត់តាំងគណៈកម្មាធិការ វាយតម្លៃពាក្យស្នើសុំប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម ឯក សុនចាន់ | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ប្រធាន |
| ២- ឯកឧត្តម សយ ភីម្បៀ | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | អនុប្រធាន |
| ៣- ឯកឧត្តម សឹម ណារ៉ា | អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្ម | អនុប្រធាន |
| ៤- លោក តាន់ សុវិទ្យា | ប្រធាននាយកដ្ឋានទឹកស្អាត | សមាជិកអចិន្ត្រៃយ៍ |
| ៥-លោក ឱ សំអែល | អគ្គាធិការរង | សមាជិក |
| ៦- លោកស្រី ផាន សោភា | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៧- លោក ចិន សេងហ៊ាង | អនុប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥)២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

**ប្រការ២ ៖**

ប្រធានគណៈកម្មាធិការមានសិទ្ធិកោះអញ្ជើញសមាជិកគណៈកម្មាធិការចូលរួមប្រជុំពិនិត្យ និងអនុម័តលើរបាយការណ៍ដែលបានសិក្សាដោយសមាជិកអចិន្ត្រៃយ៍លើសំណើសុំធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត តាមរាជធានី-ខេត្ត ដើម្បីធានាដល់ការគ្រប់គ្រងគម្រោងឲ្យបានជោគជ័យតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា របស់រាជរដ្ឋាភិបាល។ ប្រធានគណៈកម្មាធិការមានសិទ្ធផ្ទេរសិទ្ធិ ឲ្យអនុប្រធាន ឬ សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការនៅពេលដែលខ្លួនអវត្តមាន។ ដោយឡែក បើសមាជិកដែលមិនបានចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ចាត់ទុកថាបានឯកភាពលើការពិនិត្យ និងអនុម័តរបស់គណៈកម្មាធិការ។ ក្នុងករណីចាំបាច់ គណៈកម្មាធិការអាចអញ្ជើញវិនិយោគិនមកពិភាក្សាក្នុងអង្គប្រជុំពេញអង្គបាន។

**ប្រការ៣ ៖**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ គ្រប់អង្គភាពក្រោមឱវាទ និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តប្រកាសតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សាលារាជធានី-ខេត្ត
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត «*ដើម្បីជូនជ្រាប*»
- ដូចប្រការ១ «*ដើម្បីអនុវត្ត*»
- ឯកសារ-កាលប្បវត្តិ